# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០៥៥ គ.ជ.ប.ស.ជ.ណ

# សេចក្តីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ទាំង២៥ ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីចំនួន **៥២៧ រូប** សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ ដែលមានមុខតំណែង និងចំនួនដូចខាងក្រោម ៖

| | |
|---|---|
| ១- ជំនួយការរដ្ឋបាល និងលេខាធិការ | ចំនួន ២៤ រូប |
| ២- ជំនួយការគណនេយ្យ | ចំនួន ២៥ រូប |
| ៣- ជំនួយការប្រតិបត្តិការ | ចំនួន ៨ រូប |
| ៤- ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម | ចំនួន ២៥ រូប |
| ៥- លេខាធិការ | ចំនួន ២៥ រូប |
| ៦- ជំនួយការអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ (គ្រូបង្គោល) | ចំនួន ៤១៤ រូប |
| ៧- អ្នកបើកបររថយន្ត | ចំនួន ៦ រូប |

សាធារណជន ដែលមានបំណងដាក់ពាក្យសុំចូលបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញមកទទួល និងដាក់ពាក្យ សុំចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្តីជូនដំណឹងនេះ។

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ ( វេលាម៉ោង ៧:០០ ព្រឹក )
- ការឈប់ទទួលពាក្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)។/

ថ្ងៃអង្គារ ១៣រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ប្រាជ្ញ ចន្ទ

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៥៧ គ.ជ.ប. ស. វ. ៣

# សេចក្តីជូនដំណឹង
## ស្តីពី
## លក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី សម្រាប់បម្រើការងារ នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ចំនួន **៥២៧នាក់** សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២២ ដែលមានមុខតំណែង និងចំនួនដូចខាងក្រោម ៖

| ល.រ | រាជធានី ខេត្ត | ជំនួយការរដ្ឋបាល និងលេខាធិការ | ជំនួយការគណនេយ្យ | ជំនួយការប្រតិបត្តិការ | ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម | លេខាធិការ | គ្រូបង្ហាត់ | អ្នកបើកបររថយន្ត | សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ១ | ១ | ១ | ១ | ១ | ១៨ | X | ២៣ |
| ២ | បាត់ដំបង | ១ | ១ | X | ១ | ១ | ៣០ | X | ៣៤ |
| ៣ | កំពង់ចាម | ១ | ១ | X | ១ | ១ | ២០ | ១ | ២៥ |
| ៤ | កំពង់ឆ្នាំង | ១ | ១ | ១ | ១ | ១ | ១៦ | X | ២១ |
| ៥ | កំពង់ស្ពឺ | ១ | ១ | ១ | ១ | ១ | ១៦ | X | ២១ |
| ៦ | កំពង់ធំ | ១ | ១ | ១ | ១ | ១ | ១៨ | X | ២៣ |
| ៧ | កំពត | ១ | ១ | X | ១ | ១ | ១៨ | X | ២២ |
| ៨ | កណ្តាល | X | ១ | X | ១ | ១ | ២២ | ១ | ២៦ |
| ៩ | កោះកុង | ១ | ១ | X | ១ | ១ | ១៤ | X | ១៨ |
| ១០ | ក្រចេះ | ១ | ១ | ១ | ១ | ១ | ១៤ | X | ១៩ |
| ១១ | មណ្ឌលគិរី | ១ | ១ | X | ១ | ១ | ១២ | X | ១៦ |
| ១២ | ភ្នំពេញ | ១ | ១ | X | ១ | ១ | ២៨ | ១ | ៣៣ |
| ១៣ | ព្រះវិហារ | ១ | ១ | X | ១ | ១ | ១៦ | X | ២០ |
| ១៤ | ព្រៃវែង | ១ | ១ | X | ១ | ១ | ២៦ | X | ៣០ |
| ១៥ | ពោធិ៍សាត់ | ១ | ១ | ១ | ១ | ១ | ១៤ | X | ១៩ |
| ១៦ | រតនគិរី | ១ | ១ | X | ១ | ១ | ១៨ | X | ២២ |
| ១៧ | សៀមរាប | ១ | ១ | X | ១ | ១ | ២៤ | X | ២៨ |
| ១៨ | ព្រះសីហនុ | ១ | ១ | ១ | ១ | ១ | ១០ | X | ១៥ |
| ១៩ | ស្ទឹងត្រែង | ១ | ១ | X | ១ | ១ | ១២ | ១ | ១៧ |
| ២០ | ស្វាយរៀង | ១ | ១ | X | ១ | ១ | ១៦ | X | ២០ |
| ២១ | តាកែវ | ១ | ១ | ១ | ១ | ១ | ២០ | X | ២៥ |

| ល.រ | រាជធានី ខេត្ត | ជំនួយការរដ្ឋបាល និងលេខាធិការ | ជំនួយការគណនេយ្យ | ជំនួយការប្រតិបត្តិការ | ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម | លេខាធិការ | គ្រូបង្ហាត់ | អ្នកបើកបររថយន្ត | សរុប |
|---|---|---|---|---|---|---|---|---|---|
| ២២ | កែប | ១ | ១ | X | ១ | ១ | ៤ | X | ៨ |
| ២៣ | ប៉ៃលិន | ១ | ១ | X | ១ | ១ | ៤ | ១ | ៩ |
| ២៤ | ឧត្តរមានជ័យ | ១ | ១ | X | ១ | ១ | ១០ | ១ | ១៥ |
| ២៥ | ត្បូងឃ្មុំ | ១ | ១ | X | ១ | ១ | ១៤ | X | ១៨ |
| **សរុប** | | **២៤** | **២៥** | **៨** | **២៥** | **២៥** | **៤១៤** | **៦** | **៥២៧** |

I- **លក្ខខណ្ឌទូទៅនៃបេក្ខជន** ÷

- មានសញ្ញាតិខ្មែរ និងមានអាយុតាមការកំណត់ក្នុងលក្ខខណ្ឌដោយឡែក
- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ញា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសិទ្ធិបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដែលសាមីខ្លួនបានដាក់ពាក្យជាបេក្ខជន
- មានសុខភាពល្អ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ខេត្ត ឬក្នុងឃុំ សង្កាត់
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខ័ណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- បេក្ខជនអាចដាក់ពាក្យបានតែមួយមុខតំណែងគត់ ករណីឃើញថាបានដាក់ពាក្យលើសពីមួយមុខតំណែង ការដាក់ពាក្យនៅមុខតំណែងចុងក្រោយត្រូវសម្រេចយកជាផ្លូវការ
- បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត។

II- **លក្ខខណ្ឌដោយឡែក** ÷

**១- ជំនួយការរដ្ឋបាល និងលេខាធិការ** (រយៈពេលបម្រើការងារ ១-១០-២០២២ ដល់ ៣១-១-២០២៣)

- មានអាយុយ៉ាងតិច ២៣ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្ររដ្ឋបាល ឬបទពិសោធន៍ការងាររដ្ឋបាល និងលេខាធិការចាប់ពី ១ឆ្នាំ ឡើងទៅ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងមុខតំណែង ១ដង ឡើងទៅ
- ចេះសរសេររបាយការណ៍ និងកំណត់ហេតុ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**២- ជំនួយការគណនេយ្យ** (រយៈពេលបម្រើការងារ ១-៩-២០២២ ដល់ ៣១-១២-២០២២)

- មានអាយុយ៉ាងតិច ២៥ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារគណនេយ្យ និងហិរញ្ញវត្ថុ ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងគណនេយ្យ និងហិរញ្ញវត្ថុ ៣ដង ឡើងទៅ ព្រមទាំងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៣- ជំនួយការប្រតិបត្តិការ** (រយៈពេលបម្រើការងារ ១-៩-២០២២ ដល់ ៣១-១២-២០២២)

- មានអាយុយ៉ាងតិច ២៥ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងពាក់ព័ន្ធនឹងការងារប្រតិបត្តិការ ឬមានបទពិសោធន៍ការងារប្រតិបត្តិការ ចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតផ្នែកប្រតិបត្តិការ ៣ដង ឡើងទៅ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៤- ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម** (រយៈពេលបម្រើការងារ ១-១០-២០២២ ដល់ ៣១-១-២០២៣)

- មានអាយុយ៉ាងតិច ២៥ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្ររងសមស្របនឹងមុខតំណែង ឬបទពិសោធន៍ការងារច្បាប់ចាប់ពី ៣ឆ្នាំ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងវិស័យច្បាប់ ៣ដង ឡើងទៅ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៥- លេខាធិការ** (រយៈពេលបម្រើការងារ ១-៩-២០២២ ដល់ ៣១-១២-២០២២)

- មានអាយុយ៉ាងតិច ២៣ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិ ឬបទពិសោធន៍ពាក់ព័ន្ធនឹងការងារលេខាធិការចាប់ពី ១ឆ្នាំ ឡើងទៅ ឬបទពិសោធន៍ការងារបោះឆ្នោតទាក់ទងនឹងមុខតំណែង ១ដង ឡើងទៅ
- ចេះសរសេររបាយការណ៍ និងកំណត់ហេតុ
- មានការយល់ដឹង និងចេះប្រើប្រាស់កុំព្យូទ័រ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៦- ជំនួយការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងសាធារណៈ (គ្រូបង្គោល)** (រយៈពេលបម្រើការងារ ១-៩-២០២២ ដល់ ១៥-១២-២០២២)

ក- គ្រូបង្គោលដែលអាចប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ (ត្រូវការ ១នាក់ ក្នុងមួយ ក្រុង ស្រុក ខណ្ឌ)

- មានអាយុយ៉ាងតិច ២៥ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ពាក់ព័ន្ធការងារបណ្តុះបណ្តាលចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធការងារបណ្តុះបណ្តាល ៣ដង ឡើងទៅ
- ចេះប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ និងចេះប្រើប្រាស់ **Internet** និង **Email**
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងបីមុខគឺ ១- QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២- ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។

ខ- គ្រូបង្ហាត់ផ្នែកទ្រឹស្តី (ត្រូវការ ១នាក់ ក្នុងមួយ ក្រុង ស្រុក ខណ្ឌ)

- មានអាយុយ៉ាងតិច ២៥ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានសញ្ញាបត្រចាប់ពីគ្រូបឋមសិក្សាឡើងទៅ ឬមានបទពិសោធន៍ពាក់ព័ន្ធការងារបណ្តុះបណ្តាលចាប់ពី ៣ឆ្នាំ ឬមានបទពិសោធន៍ការងារបោះឆ្នោតពាក់ព័ន្ធការងារបណ្តុះបណ្តាល ៣ដង ឡើងទៅ (អាចប្រើប្រាស់កុំព្យូទ័របានកាន់តែប្រសើរ)
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៥០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។

**៧- អ្នកបើកបររថយន្ត** (រយៈពេលបម្រើការងារ ១-៩-២០២២ ដល់ ៣១-១២-២០២២)

- មានអាយុយ៉ាងតិច ២២ ឆ្នាំ (គិតចាប់ពីថ្ងៃចូលបម្រើការងារ)
- មានប័ណ្ណបើកបររថយន្ត
- មានបទពិសោធន៍ក្នុងការងារបើកបរចាប់ពី ២ឆ្នាំឡើងទៅ
- ចេះអាន ចេះសរសេរអក្សរខ្មែរ និងមានអ្នកធានាទទួលស្គាល់គួរជាទីទុកចិត្តបាន
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.២០០.០០០ រៀល
- មុខតំណែងនេះ ត្រូវប្រឡងមួយមុខគឺ សម្ភាសន៍។

## III- ទំនាក់ទំនងព័ត៌មាន

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យសុំប្រឡងចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Cod លើសេចក្តីជូនដំណឹងផ្សព្វផ្សាយ។

## IV- កាលបរិច្ឆេទនៃការទទួលពាក្យ ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនប្រឡង និងការប្រឡង

- ការចាប់ផ្តើមទទួលពាក្យ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ (វេលាម៉ោង ៧:០០ នាទីព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- រាជធានី និងខេត្តក្រុមទី១ ត្រូវធ្វើការពិនិត្យពាក្យ និងសម្រាំងបេក្ខជន និងបិទផ្សាយបញ្ជីឈ្មោះប្រឡងនៅថ្ងៃទី១៣-១៤ ខែសីហា ឆ្នាំ២០២២ នឹងប្រឡង នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ រួមមាន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តកែប រាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តមណ្ឌលគិរី ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ
- ខេត្តក្រុមទី២ ត្រូវធ្វើការពិនិត្យពាក្យ និងសម្រាំងបេក្ខជន និងបិទផ្សាយបញ្ជីឈ្មោះប្រឡង នៅថ្ងៃទី១៥-១៦ ខែសីហា ឆ្នាំ២០២២ នឹងប្រឡងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២២ រួមមាន ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តស្ទឹងត្រែង ខេត្តព្រះសីហនុ ខេត្តកណ្តាល ខេត្តត្បូងឃ្មុំ ខេត្តកោះកុង ខេត្តស្វាយរៀង ខេត្តកំពត ខេត្តរតនគិរី ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងខេត្តព្រះវិហារ ។

## V- ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អនុគណៈកម្មការរៀបចំការប្រឡង ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជនដោយត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនណាដែលមានលក្ខខណ្ឌល្អជាងគេមកប្រឡង និងសម្ភាសន៍។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវបានប្រគល់ជូនវិញទេ។

## VI- លទ្ធផលនៃការប្រឡង និងសម្ភាសន៍

លទ្ធផលនៃការប្រឡង និងសម្ភាសន៍នឹងបិទផ្សាយនៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត។

**<u>បញ្ជាក់បន្ថែម</u> ÷**

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮយ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា «... មន្ត្រីរាជការដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល»
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ថ្ងៃអង្គារ ១៣រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ប្រាជ្ញ ចន្ទ